KH/2010/CL/CON3/31
Phnom Penh, October 2010
Original: English

អនុសញ្ញា

# អនុសញ្ញា

## ស្តីពីការការពារ និងការលើកស្ទួយ

# ភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

UNESCO
United Nations
Educational, Scientific and
Cultural Organization

# អនុសញ្ញា

## ស្តីពីការការពារ
## និងការលើកស្ទួយ

# ភាពផ្សេងៗគ្នា
# នៃវិញ្ញត្តិវប្បធម៌

ទីក្រុងប៉ារីស ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥

សន្និសីទទូទៅ នៃអង្គការយូណេស្កូ ដែលបានធ្វើឡើងនៅទីក្រុងប៉ារីស ពីថ្ងៃទី០៣ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ សម្រាប់សម័យប្រជុំលើកទី៣៣របស់ខ្លួន,

*ដោយអះអាងថា* ភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាចរិតលក្ខណៈមួយមានពីកំណើតរបស់មនុស្សជាតិ,

*ដោយយល់ឃើញថា* ភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាបេតិកភណ្ឌរួមរបស់មនុស្សជាតិ និងគួរតែត្រូវបានលើកតម្កើង និងថែរក្សា ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិទាំងអស់,

*ដោយដឹងថា* ភាពផ្សេងៗគ្នានៃវប្បធម៌បង្កើតបានពិភពមួយពោរពេញទៅដោយភាពសំបូរបែប និងភាពប្លែកៗគ្នាដែលពង្រីកនូវលទ្ធភាពជម្រើសបានច្រើន បណ្តុះនូវសមត្ថភាព និងតម្លៃមនុស្ស ហើយភាពផ្សេងៗគ្នានៃវប្បធម៌គឺជាកំលាំងគ្រឹះនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃសហគមន៍ប្រជាជន និងប្រជាជាតិ,

*ដោយរំលឹកឡើងវិញថា* ភាពផ្សេងៗគ្នានៃវប្បធម៌ដែលរីកលូតលាស់នៅក្នុងក្របខ័ណ្ឌនៃលទ្ធិប្រជាធិបតេយ្យ ភាពសណ្តោសអត់ឱន យុត្តិធម៌សង្គម និងការគោរពគ្នាទៅវិញទៅមករវាងប្រជាជន និង ប្រជាជន រវាងវប្បធម៌ និងវប្បធម៌ គឺជាកត្តាចាំបាច់ខានមិនបានដល់សន្តិភាព និង សន្តិសុខក្នុងតំបន់ ជាតិ និងអន្តរជាតិ,

*ដោយលើកតម្កើង* សារៈសំខាន់នៃភាពផ្សេងៗគ្នានៃវប្បធម៌ដើម្បីធ្វើឲ្យសម្រេចបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានប្រកាសនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ក៏ដូចជានៅក្នុងលិខិតូបករណ៍ដទៃទៀតដែលត្រូវបានទទួលស្គាល់ជាសាកល,

*ដោយគូសបញ្ជាក់* ពីភាពចាំបាច់ក្នុងការធ្វើសមាហរណកម្មវប្បធម៌ជាធាតុផ្សំយុទ្ធសាស្ត្រទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំងទៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍន៍ ដោយចាប់អារម្មណ៍ផងដែរទៅលើសេចក្តីថ្លែងការណ៍សហសវត្សរបស់អង្គការសហប្រជាជាតិ(ឆ្នាំ២០០០) ដែលផ្តោតលើការលុបបំបាត់ភាពក្រីក្រ,

*ដោយសង្កេតឃើញថា* វប្បធម៌មានទម្រង់ប្លែកៗគ្នាទៅតាមកាលវេលា និងទីកន្លែង ហើយដោយសង្កេតឃើញថា ភាពប្លែកៗគ្នានេះចាប់បដិសន្ធិឡើងនៅក្នុងភាពថ្មីប្លែកពីគេ និងក្នុងពហុភាពនៃអត្តសញ្ញាណ ព្រមទាំងនៅក្នុងវិញ្ញត្តិវប្បធម៌របស់ប្រជាជាន និងសង្គមដែលរួមផ្សំ បង្កើតជាមនុស្សជាតិ,

*ដោយទទួលស្គាល់* សារៈសំខាន់នៃចំណេះដឹងជាប្រពៃណី ជាប្រភពនៃធនធានអរូបី និងរូបី និងជាពិសេសសារៈសំខាន់នៃប្រព័ន្ធចំណេះដឹងរបស់ប្រជាជនម្ចាស់ស្រុកហើយដោយទទួលស្គាល់នូវការរួមចំណែកជាវិជ្ជមាននៃចំណេះដឹងទាំងនេះដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងភាពចាំបាច់ក្នុងការការពារ និងលើកស្ទួយចំណេះដឹងទាំងនេះឲ្យបានសមស្រប,

*ដោយទទួលស្គាល់* ភាពចាំបាច់ក្នុងការចាត់វិធានការដើម្បីការពារភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌រួមទាំងខ្លឹមសារចម្រុះរបស់វាផងដែរ ជាពិសេសនៅក្នុងស្ថានភាពដែលភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌អាចទទួលរងនូវការគំរាមកំហែងផុតរលត់ ឬការខូចខាតធ្ងន់ធ្ងរ,

*ដោយកត់សំគាល់ឃើញពី* សារៈសំខាន់របស់វប្បធម៌ក្នុងការធ្វើឲ្យមានសាមគ្គីភាពក្នុងសង្គមជាទូទៅនិងជាពិសេសការចូលរួមចំណែករបស់វប្បធម៌ក្នុងការលើកស្ទួយឋានៈ និងតួនាទីរបស់ស្ត្រីនៅក្នុងសង្គម,

*ដោយយល់ឃើញថា* ភាពផ្សេងៗគ្នានៃវប្បធម៌ត្រូវបានពង្រឹងដោយការផ្លាស់ប្តូរគំនិតគ្នាដោយសេរី និងដោយយល់ឃើញថាភាពផ្សេងៗគ្នានៃវប្បធម៌ធ្វើឲ្យមានការផ្លាស់ប្តូរជាច្រើនព្រមទាំងធ្វើឲ្យមានអន្តរកម្ម រវាងវប្បធម៌ និងវប្បធម៌,

*ដោយបញ្ជាក់ឡើងវិញថា* សេរីភាពនៃការគិត ការបញ្ចេញមតិ និងការទទួលបានព័ត៌មាន ព្រមទាំងពហុប្រព័ន្ធផ្សព្វផ្សាយអាចធ្វើឲ្យមានការរីកលូតលាស់ដល់វិញ្ញត្តិវប្បធម៌នៅក្នុងសង្គមនីមួយៗ,

*ដោយទទួលស្គាល់ថា* ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ រួមទាំងវិញ្ញត្តិវប្បធម៌ជាលក្ខណៈប្រពៃណីនានា គឺជាកត្តាដ៏សំខាន់ដែលអនុញ្ញាតឲ្យបុគ្គលម្នាក់ៗ និងប្រជាជនធ្វើការបកស្រាយ បង្ហាញ និងចែករំលែកគំនិត ព្រមទាំងតម្លៃរបស់ខ្លួនជាមួយអ្នកដទៃ,

*ដោយរំលឹកឡើងវិញថា* ភាពផ្សេងៗគ្នានៃភាសា គឺជាធាតុផ្សំគ្រឹះមួយនៃភាពផ្សេងៗគ្នានៃវប្បធម៌និងដោយបញ្ជាក់ឡើងវិញពីតួនាទីជាមូលដ្ឋាននៃការអប់រំនៅក្នុងការការពារ និងការលើកស្ទួយនូវវិញ្ញត្តិវប្បធម៌នានា,

*ដោយសង្កេតឃើញពី* សារៈសំខាន់នៃភាពក្លៀវក្លារបស់វប្បធម៌សម្រាប់មនុស្សទាំងអស់គ្នា រួមទាំងសម្រាប់មនុស្សក្នុងក្រុមជនជាតិភាគតិច និងសម្រាប់ប្រជាជនម្ចាស់ស្រុក ដូចដែលវាស្តែងឡើងតាមរយៈសេរីភាពរបស់ពួកគេក្នុងការបង្កើតផ្សព្វផ្សាយ និងចែកចាយនូវ វិញ្ញត្តិវប្បធម៌ជាលក្ខណៈប្រពៃណីរបស់ពួកគេ និងចូលរួមដើម្បីជួយសម្រួលដល់ការអភិវឌ្ឍន៍របស់ខ្លួនគេផ្ទាល់,

*ដោយកត់សំគាល់ឃើញ* ពីតួនាទីដ៏សំខាន់នៃអន្តរកម្ម និងគំនិតច្នៃប្រឌិតផ្នែកវប្បធម៌ដែលបណ្តុះ និងបង្កើតថ្មីឡើងវិញនូវវិញ្ញត្តិវប្បធម៌ ព្រមទាំងពង្រឹងតួនាទីរបស់បុគ្គលដែលធ្វើការដើម្បីអភិវឌ្ឍវប្បធម៌ សំដៅឈានទៅរកវឌ្ឍនភាពក្នុងសង្គមទាំងមូល,

*ដោយទទួលស្គាល់ពី* សារៈសំខាន់នៃសិទ្ធិលើកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់បុគ្គលទាំងឡាយដែលចូលរួមក្នុងការច្នៃប្រឌិត បង្កើតថ្មីផ្នែកវប្បធម៌,

*ដោយជឿជាក់ថា* សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌មានធម្មជាតិពីរ គឺសេដ្ឋកិច្ចនិងវប្បធម៌ ព្រោះវាបង្កប់ទៅដោយអត្តសញ្ញាណ តម្លៃ និងអត្ថន័យ ហើយអាស្រ័យហេតុនេះ សកម្មភាពទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ទាំងនេះ មិនត្រូវចាត់ទុកថាមានតម្លៃត្រឹមតែខាងពាណិជ្ជកម្មតែមួយមុខឡើយ,

*ដោយសង្កេតឃើញថា* ចរន្តសាកលភាវូបនីយកម្ម ដែលត្រូវបានសម្រួលដោយការវិវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ប្រសិនបើវាបង្កើតជាល័ក្ខខ័ណ្ឌថ្មីនៃអន្តរកម្មដែលត្រូវបានពង្រឹងរវាងវប្បធម៌ និងវប្បធម៌ ចរន្តនេះបង្កជាបញ្ហាប្រឈមសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ ជាពិសេសហានិភ័យនៃអតុល្យភាពរវាងប្រទេសអ្នកមាន និងប្រទេសអ្នកក្រ,

*ដោយឈ្វេងយល់ពី* អាណត្តិពិសេសដែលប្រគល់ដល់អង្គការយូណេស្កូ ក្នុងការធានាឲ្យមានការគោរពភាពផ្សេងៗគ្នានៃវប្បធម៌ និងផ្តល់អនុសាសន៍ឲ្យមានកិច្ចព្រមព្រៀងអន្តរជាតិដែលអង្គការយល់ថាមានសារៈប្រយោជន៍ដើម្បីសម្រួលឲ្យមានការផ្លាស់ប្តូរគំនិតគ្នាដោយសេរីតាមរយៈពាក្យសំដីនិងរូបភាព,

*ដោយយោងលើ* បទប្បញ្ញត្តិនៃលិខិតូបករណ៍អន្តរជាតិនានាដែលអនុម័តដោយអង្គការយូណេស្កូពាក់ព័ន្ធនឹងភាពផ្សេងៗគ្នានៃវប្បធម៌និងការអនុវត្តន៍សិទ្ធិផ្នែកវប្បធម៌ និងជាពិសេសដោយយោងលើសេចក្តីថ្លែងការណ៍ជាសាកលស្តីពីភាពផ្សេងៗគ្នានៃវប្បធម៌ ឆ្នាំ២០០១ សន្និសីទកំពូលលើកទី៣៣ របស់អង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងប៉ារីស ពីថ្ងៃទី០៣ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ បានអនុម័តអនុសញ្ញានេះ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ ៖

# ១. គោលដៅ និង គោលការណ៍តម្រង់ទិស

## មាត្រា ១ - គោលដៅ

អនុសញ្ញានេះមានគោលដៅៈ

(ក) ការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវប្បធម៌;

(ខ) បង្កើតជាល័ក្ខខ័ណ្ឌដែលអាចឲ្យវប្បធម៌រីកលូតលាស់ និងមានអន្តរកម្មដោយសេរី សំដៅធ្វើឲ្យវប្បធម៌ទាំងអស់មានលក្ខណៈសំបូរបែបទៅវិញទៅមក;

(គ) លើកទឹកចិត្តឲ្យមានទំនាក់ទំនងរវាងវប្បធម៌ និងវប្បធម៌ ដើម្បីធានាឲ្យមានការផ្លាស់ប្តូរវប្បធម៌គ្នាឲ្យកាន់តែខ្លាំងក្លាឡើង និងមានតុល្យភាពនៅក្នុងពិភពលោក សំដៅឲ្យមានការគោរពអន្តរវប្បធម៌ និងវប្បធម៌សន្តិភាព;

(ឃ) ជំរុញអន្តរភាពវប្បធម៌ ដើម្បីអភិវឌ្ឍអន្តរកម្មវប្បធម៌នៅក្នុងស្មារតីកសាងស្ពានទំនាក់ទំនងរវាង ប្រជាជន និងប្រជាជន;

(ង) លើកកំពស់ការគោរពភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ និងការយល់ដឹងពីតម្លៃរបស់វា ក្នុងកំរិតតំបន់ ជាតិ និងអន្តរជាតិ;

(ច) ធ្វើការបញ្ជាក់ឡើងវិញពីសារៈសំខាន់នៃចំណងទាក់ទងរវាងវប្បធម៌ និងការអភិវឌ្ឍន៍ សម្រាប់គ្រប់ប្រទេសទាំងអស់ ជាពិសេសប្រទេសកំពុងអភិវឌ្ឍ និងជំរុញរាល់សកម្មភាពដែលធ្វើឡើងនៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីធ្វើឲ្យតម្លៃដ៏ពិតប្រាកដនៃចំណងទាក់ទងនេះត្រូវបានទទួលស្គាល់;

(ឆ) ទទួលស្គាល់ធម្មជាតិពិសេសនៃសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ជាវត្ថុរក្សាអត្តសញ្ញាណ តម្លៃ និងអត្ថន័យ;

(ជ) ធ្វើការបញ្ជាក់ឡើងវិញពីសិទ្ធិអធិបតេយ្យរបស់រដ្ឋនានាក្នុងការអភិរក្ស អនុម័ត និងអនុវត្តគោលនយោបាយ និងវិធានការដែលខ្លួនយល់ថាសមស្របសម្រាប់ការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌នៅលើទឹកដីនៃរដ្ឋទាំងនោះ;

(ឈ) ពង្រឹងកិច្ចសហប្រតិបត្តិការ និងចំណងសាមគ្គីភាពជាអន្តរជាតិ នៅក្នុងស្មារតីភាពជាដៃគូ ដើម្បីបង្កើនសមត្ថភាព របស់ប្រទេសកំពុងអភិវឌ្ឍក្នុងការការពារ និងលើកលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

## មាត្រា ២ - គោលការណ៍តម្រង់ទិស

### ១- គោលការណ៍គោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

ភាពផ្សេងៗគ្នានៃវប្បធម៌អាចត្រូវបានការពារ និងលើកស្ទួយ លុះត្រាតែសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចជាសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន និងប្រាស្រ័យទាក់ទង ក៏ដូចជាលទ្ធភាពរបស់បុគ្គលគ្រប់រូបក្នុងការជ្រើសរើសវិញ្ញត្តិវប្បធម៌ ត្រូវបានធានា។ គ្មានបុគ្គលណាម្នាក់អាចលើកពីបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដើម្បីធ្វើឲ្យប៉ះពាល់ដល់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ឬធានាដោយនីតិអន្តរជាតិ ឬដើម្បីដាក់កំរិតអានុភាពនៃសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានបានឡើយ។

## ២- គោលការណ៍អធិបតេយ្យភាព

អនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងគោលការណ៍នៃនីតិអន្តរជាតិ រដ្ឋនីមួយៗមានសិទ្ធិអធិបតេយ្យក្នុងការអនុម័តរាល់វិធានការនិងគោលនយោបាយ ដើម្បីការពារនិងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌នៅលើទឹកដីនៃរដ្ឋនោះ ។

## ៣- គោលការណ៍នៃសេចក្តីថ្លៃថ្នូរដោយស្មើភាពគ្នា និងគោលការណ៍គោរពវប្បធម៌ទាំងអស់

ការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌តម្រូវឲ្យមានការទទួលស្គាល់សេចក្តីថ្លៃថ្នូរដោយស្មើភាពគ្នា និងការគោរពវប្បធម៌ទាំងអស់ រួមទាំងវប្បធម៌របស់ក្រុមជនជាតិភាគតិច និងវប្បធម៌របស់ប្រជាជនម្ចាស់ស្រុកផងដែរ ។

## ៤- គោលការណ៍សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការ និងសាមគ្គីភាពអន្តរជាតិគប្បីអនុញ្ញាតឲ្យប្រទេសទាំងអស់ ជាពិសេសប្រទេសកំពុងអភិវឌ្ឍអាចបង្កើត និងពង្រឹងមធ្យោបាយចាំបាច់ដល់វិញ្ញត្តិវប្បធម៌របស់ពួកគេ រួមទាំងឧស្សាហកម្មវប្បធម៌របស់ពួកគេ ទោះជាកើតឡើងដោយឯកឯង ឬត្រូវបានបង្កើតឡើងក្នុងកម្រិតតំបន់ ជាតិ និងអន្តរជាតិក៏ដោយ ។

## ៥- គោលការណ៍បំពេញបន្ថែមរវាងទិដ្ឋភាពសេដ្ឋកិច្ច និងទិដ្ឋភាពវប្បធម៌នៃការអភិវឌ្ឍ

ដោយសារវប្បធម៌ គឺជាកំលាំងគ្រឹះនៃការអភិវឌ្ឍ ទិដ្ឋភាពវប្បធម៌នៃការអភិវឌ្ឍក៏មានសារៈសំខាន់ដូចទិដ្ឋភាពសេដ្ឋកិច្ចដែរ ហើយបុគ្គលគ្រប់រូប និងប្រជាជនមានសិទ្ធិជាមូលដ្ឋានក្នុងការចូលរួម ឬទាញយកអត្ថប្រយោជន៍ពីវា ។

## ៦- គោលការណ៍អភិវឌ្ឍប្រកបដោយនិរន្តរភាព

ភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាធនធានដ៏ធំមួយសម្រាប់មនុស្សគ្រប់រូប និងសង្គមជាតិ ។ ការការពារ ការលើកស្ទួយ និងការថែរក្សាភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាល័ក្ខខ័ណ្ឌមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពជាប្រយោជន៍ដល់មនុស្សជំនាន់នេះ និងជំនាន់ក្រោយ ។

## ៧- គោលការណ៍នៃសិទ្ធិទទួលបានប្រកបដោយសមធម៌

សិទ្ធិនៃការទទួលបានប្រកបដោយសមធម៌នូវបណ្តុំដ៏សំបូរបែប និងចម្រុះគ្នានៃវិញ្ញត្តិវប្បធម៌ ដែលមានប្រភពមកពីពិភពលោកទាំងមូល ព្រមទាំងសិទ្ធិនៃការទទួលបានវប្បធម៌ តាមរយៈមធ្យោបាយនៃវិញ្ញត្តិ និងការផ្សព្វផ្សាយ គឺជាធាតុដ៏សំខាន់ ដើម្បីលើកតម្លៃភាពផ្សេងៗគ្នានៃវប្បធម៌និងជំរុញឲ្យមានការយោគយល់គ្នាទៅវិញទៅមក។

## ៨- គោលការណ៍បើកចំហ និងតុល្យភាព

នៅពេលរដ្ឋទាំងអស់អនុម័តទទួលយកវិធានការ សំដៅបង្កលក្ខណៈអនុគ្រោះដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ បណ្តារដ្ឋទាំងអស់គប្បីយកចិត្តទុកដាក់ក្នុងការលើកកម្ពស់នៃការបើកចំហដល់វប្បធម៌ដទៃទៀតរបស់ពិភពលោកឲ្យបានសមស្រប និងធានាថាវិធានការទាំងនេះមានភាពត្រឹមត្រូវ ស្របតាមគោលដៅដែលអនុសញ្ញានេះចង់បាន ។

## ២. ដែនអនុវត្តន៍

### មាត្រា ៣ - គោលដៅ

អនុសញ្ញានេះអនុវត្តនឹចំពោះគោលនយោបាយ និងវិធានការដែលអនុម័តដោយរដ្ឋភាគីពាក់ព័ន្ធនឹងការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

## ៣. និយមន័យ

### មាត្រា ៤ - និយមន័យ

ដើម្បីបម្រើគោលដៅនៃអនុសញ្ញានេះ ពាក្យដែលប្រើប្រាស់មួយចំនួនមានអត្ថន័យដូចតទៅ៖

#### ១- ភាពផ្សេងៗគ្នានៃវប្បធម៌

ពាក្យថា "ភាពផ្សេងៗគ្នានៃវប្បធម៌" សំដៅដល់ពហុភាពនៃទម្រង់ ដែលតាមរយៈនោះ វប្បធម៌របស់ក្រុមមនុស្ស និងសង្គមអាចស្វែងរកឃើញនូវវិញ្ញត្តិរបស់ខ្លួន ។ វិញ្ញត្តិទាំងនេះនឹងផ្ទេរបន្តទៅឲ្យគ្នាទៅវិញទៅមកក្នុងចំណោមក្រុមមនុស្ស និងសង្គម ហើយរវាងសង្គម និងសង្គម ។

ភាពផ្សេងៗគ្នានៃវប្បធម៌ មិនត្រឹមតែស្តែងឡើងនៅក្នុងទម្រង់ប្លែកៗគ្នា ដែលតាមរយៈនោះបេតិកភណ្ឌវប្បធម៌របស់មនុស្សជាតិត្រូវបានសំដែងចេញ ត្រូវបានធ្វើឲ្យកាន់តែមានភាពសំបូរបែប និងត្រូវបានផ្ទេរអាស្រ័យដោយសារមានភាពខុសគ្នានៃវិញ្ញត្តិវប្បធម៌ប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈវិធីផ្សេងៗក្នុងការបង្កើតស្នាដៃសិល្បៈ ការផលិត ការផ្សព្វផ្សាយ ការចែកចាយ និងការអាស្រ័យផលពីវិញ្ញត្តិវប្បធម៌នានា ទោះបីជាប្រើប្រាស់មធ្យោបាយ និងបច្ចេកវិទ្យាបែបណាក៏ដោយ។

#### ២- ខ្លឹមសារវប្បធម៌

ពាក្យថា "ខ្លឹមសារវប្បធម៌" សំដៅដល់អត្ថន័យជានិមិត្តរូបដល់ទំហំនៃសិល្បៈ និងដល់តម្លៃនៃវប្បធម៌ ដែលមានប្រភពដើម ឬបង្ហាញពីអត្តសញ្ញាណវប្បធម៌ ។

#### ៣- វិញ្ញត្តិវប្បធម៌

ពាក្យថា "វិញ្ញត្តិវប្បធម៌" សំដៅដល់វិញ្ញត្តិដែលកើតចេញពីគំនិតច្នៃប្រឌិតរបស់បុគ្គលម្នាក់ៗរបស់ក្រុមមនុស្ស និងសង្គម ហើយមានបង្កប់នូវខ្លឹមសារវប្បធម៌ ។

#### ៤- សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌

ពាក្យថា "សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌" សំដៅដល់សកម្មភាពទ្រព្យសម្បត្តិ និងសេវាកម្មដែលនិមិត្តតំណាង ឬផ្ទេរនូវវិញ្ញត្តិវប្បធម៌នានា ដោយមិនអាស្រ័យនឹងតម្លៃខាងពាណិជ្ជកម្មដែលអាចមានឡើយចាប់ពីពេលដែលសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មទាំងនេះត្រូវបានយកចិត្តទុកដាក់ខាងផ្នែកគុណភាព បម្រើបម្រាស់ ឬគោលដៅពិសេសរបស់វា ។ សកម្មភាពវប្បធម៌អាចមិនបញ្ចប់ត្រឹមនេះទេ ឬអាចរួមចំណែកក្នុងការផលិតទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ទៀតផង ។

### ៥- ឧស្សាហកម្មវប្បធម៌

ពាក្យ "ឧស្សាហកម្មវប្បធម៌" សំដៅដល់ឧស្សាហកម្មដែលផលិត និងចែកចាយទ្រព្យសម្បត្តិឬសេវាកម្មវប្បធម៌ ដូចដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី៤ខាងលើ ។

### ៦- គោលនយោបាយ និងវិធានការវប្បធម៌

ពាក្យថា "គោលនយោបាយ និងវិធានការវប្បធម៌" សំដៅដល់គោលនយោបាយ និងវិធានការ ដែលពាក់ព័ន្ធនឹងវប្បធម៌ក្នុងកម្រិតមូលដ្ឋាន ជាតិ តំបន់ ឬអន្តរជាតិ ទោះជាគោលនយោបាយ និងវិធានការទាំងនេះផ្តោតលើវប្បធម៌ ឬប្រើសម្រាប់ជះឥទ្ធិពលដោយផ្ទាល់ទៅលើវិញ្ញត្តិវប្បធម៌របស់បុគ្គលម្នាក់ៗ ក្រុមមនុស្ស ឬសង្គម រួមទាំងទៅលើការបង្កើតការផលិត ការផ្សព្វផ្សាយ និងការចែកចាយសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ និងលើការទទួលបានផលពីអ្វីៗទាំងនេះក៏ដោយ ។

### ៧- ការការពារ

ពាក្យថា "ការការពារ" មានន័យថាការអនុម័តយល់ព្រមទទួលយកវិធានការដែលសំដៅធ្វើការអភិរក្សការថែរក្សា និងការលើកតម្លៃភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

"ការពារ" មានន័យថាអនុម័តយល់ព្រមទទួលយកវិធានការទាំងនោះ ។

### ៨- អន្តរវប្បធម៌ភាព

"អន្តរវប្បធម៌ភាព" សំដៅដល់អត្ថិភាព និងអន្តរកម្មប្រកបដោយសមធម៌នៃវប្បធម៌ផ្សេងៗ ព្រមទាំងលទ្ធភាពបង្កើតឲ្យមានជាវិញ្ញត្តិវប្បធម៌ដែលចែករំលែកដោយទំនាក់ទំនងគ្នា និងការគោរពគ្នាទៅវិញទៅមក ។

# ៤. សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគី

## មាត្រា ៥ - វិធានទូទៅពាក់ព័ន្ធនឹងសិទ្ធិ និងកាតព្វកិច្ច

១- ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ គោលការណ៍នៃនីតិអន្តរជាតិ និងលិខិតូបករណ៍ ដែលត្រូវបានទទួលស្គាល់ជាសាកលក្នុងវិស័យសិទ្ធិមនុស្ស រដ្ឋភាគីទាំងអស់បញ្ជាក់អះអាងជាថ្មីថា សិទ្ធិអធិបតេយ្យក្នុងការរៀបចំគាក់តែង និងការអនុវត្តន៍នូវគោលនយោបាយវប្បធម៌របស់ខ្លួន និងអនុម័តទទួលយកវិធានការដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ព្រមទាំងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅឈានទៅសម្រេចឲ្យបាននូវគោលដៅនៃអនុសញ្ញានេះ ។

២- នៅពេលដែលរដ្ឋភាគីណាមួយអនុវត្តគោលនយោបាយ និងចាត់វិធានការដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ នៅលើដែនដីរបស់ខ្លួន ពេលនោះគោលនយោបាយ និងវិធានការរបស់រដ្ឋភាគីនោះត្រូវតែស្របគ្នាទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ។

## មាត្រា ៦ - សិទ្ធិរបស់រដ្ឋភាគីទាំងអស់នៅថ្នាក់ជាតិ

១- នៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយ និងវិធានការវប្បធម៌ ដូចដែលបានរៀបរាប់នៅក្នុងមាត្រា៤.៦និងដោយយោងទៅលើកាលៈទេសៈ ព្រមទាំងតម្រូវការរបស់ខ្លួនផ្ទាល់ រដ្ឋភាគីនីមួយៗអាចអនុម័តទទួលយកវិធានការសម្រាប់ការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ នៅលើដែនដីរបស់ខ្លួន ។

២- វិធានការនេះអាចរួមបញ្ចូលៈ

(ក) រាល់វិធានការជាបទបញ្ញាដែលមានគោលដៅការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌;

(ខ) រាល់វិធានការដែលផ្តល់កាលានុវត្តភាពយ៉ាងសមស្របដល់សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ជាតិឲ្យមានវត្តមានក្នុងចំណោមសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ទាំងអស់ដែលមាននៅក្នុងដែនដីរបស់ខ្លួនពាក់ព័ន្ធនឹងការបង្កើត ការផលិត ការផ្សព្វផ្សាយ ការចែកចាយ និងការអាស្រ័យផលរួមទាំងវិធានការពាក់ព័ន្ធនឹងភាសាប្រើប្រាស់សម្រាប់សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មទាំងអស់ខាងលើនេះ;

(គ) រាលវិធានការដែលមានគោលដៅផ្តល់ដល់ឧស្សាហកម្មវប្បធម៌ជាតិឯករាជ្យ និងដល់សកម្មភាពនៃវិស័យក្រៅផ្លូវការនូវការទទួលផលបានដ៏ពិតប្រាកដ នៃមធ្យោបាយផលិតកម្ម ការផ្សព្វផ្សាយ និងការចែកចាយសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌;

(ឃ) រាល់វិធានការដែលមានគោលដៅផ្តល់ជំនួយហិរញ្ញវត្ថុសាធារណៈ;

(ង) រាល់វិធានការដែលមានគោលដៅជំរុញ បណ្តាអង្គការដែលគ្មានគោលបំណងស្វែងរកផលចំណេញ ព្រមទាំងស្ថាប័នសាធារណៈ និងស្ថាប័នឯកជន សិល្បករ និងអ្នកវិជ្ជាជីវៈខាងវប្បធម៌ដទៃទៀតឲ្យចូលរួមអភិវឌ្ឍ និងលើកស្ទួយការប្តូរដោយសេរី និង ការផ្លាស់ប្តូរគំនិតដោយសេរី និងវិញ្ញត្តិវប្បធម៌ ព្រមទាំងសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ និងជំរុញឲ្យមានការបង្កើត និងមានគំនិតផ្តួចផ្តើមនៅក្នុងសកម្មភាពរបស់ខ្លួន;

(ច) រាល់វិធានការដែលមានគោលដៅបង្កើត និងគាំទ្រយ៉ាងសមស្របដល់បណ្តាស្ថាប័នផ្តល់សេវាសាធារណៈ;

(ឆ) រាល់វិធានការដែលមានគោលដៅជំរុញ និងគាំទ្រសិល្បករព្រមទាំងបុគ្គលដែលចូលរួមនៅក្នុងការបង្កើតឡើងនូវវិញ្ញត្តិវប្បធម៌;

(ជ) រាល់វិធានការដែលមានគោលដៅលើកស្ទួយពហុប្រព័ន្ធផ្សព្វផ្សាយ រួមទាំងតាមរយៈសេវាសាធារណៈ ផ្នែកវិទ្យុផ្សព្វផ្សាយ ។

## មាត្រា ៧ - វិធានការសម្រាប់លើកស្ទួយវិញ្ញត្តិវប្បធម៌

១- រដ្ឋភាគីទាំងអស់ ព្យាយាមបង្កើតនៅលើទឹកដីរបស់ខ្លួន នូវបរិស្ថានមួយដែលលើកទឹកចិត្តដល់បុគ្គលគ្រប់រូប និងក្រុមសង្គមមនុស្សឲ្យៈ

(ក) បង្កើត ផលិត ផ្សព្វផ្សាយ និងចែកចាយវិញ្ញត្តិវប្បធម៌ផ្ទាល់របស់ខ្លួននិងបានចូលរួមក្នុងនោះដោយផ្តោតការយកចិត្តទុកដាក់ដល់ល័ក្ខខ័ណ្ឌ និងតម្រូវការពិសេសរបស់ស្ត្រី ព្រមទាំងក្រុមសង្គមមនុស្សផ្សេងៗទៀត រួមទាំងក្រុមជនជាតិភាគតិច និងប្រជាជនម្ចាស់ស្រុក ;

(ខ) បានចូលរួមក្នុងរាល់វិញ្ញត្តិវប្បធម៌ផ្សេងៗ ដែលមានប្រភពដើមនៅក្នុងដែនដីរបស់ខ្លួនក៏ដូចជាក្នុងប្រទេសដទៃទៀតនៅលើពិភពលោក ។

២- រដ្ឋភាគីទាំងអស់ក៏ព្យាយាមផងដែរ ក្នុងការទទួលស្គាល់ការរួមចំណែកដ៏សំខាន់របស់សិល្បករ និងបុគ្គលគ្រប់រូប ដែលបានចូលរួមនៅក្នុងដំណើរនៃការច្នៃប្រឌិតបង្កើតថ្មីរបស់បណ្តាសហគមន៍វប្បធម៌ និងបណ្តាអង្គការដែលគាំទ្រដល់សហគមន៍វប្បធម៌ទាំងនោះ នៅក្នុងការងាររបស់ពួកគេ ព្រមទាំងតួនាទីស្នូលរបស់ពួកគេក្នុងការបណ្តុះនូវភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

## មាត្រា ៨ - វិធានការសម្រាប់ការពារវិញ្ញត្តិវប្បធម៌

១- រដ្ឋភាគីមួយអាចវិភាគវិនិច្ឆ័យពីអត្ថិភាពនៃស្ថានភាពពិសេស ដែលវិញ្ញត្តិវប្បធម៌នៅលើដែនដីរបស់ខ្លួនមានការប្រឈមចំពោះគ្រោះនៃការផុតរលត់ ការគំរាមកំហែងធ្ងន់ធ្ងរ ឬទាមទារឲ្យមានការអភិរក្សជាបន្ទាន់ ទោះជាតាមរបៀបណាក៏ដោយ ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃមាត្រា ៥ និងមាត្រា ៦ ។

២- រដ្ឋភាគីទាំងអស់អាចចាត់វិធានការសមស្របគ្រប់បែបយ៉ាង ដើម្បីការពារ និងថែរក្សាវិញ្ញត្តិវប្បធម៌ នៅក្នុងស្ថានភាពដែលមានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី ១ ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ ។

៣- រដ្ឋភាគីទាំងអស់ធ្វើរបាយការណ៍ជូនគណៈកម្មាធិការអន្តររដ្ឋាភិបាល ដូចមានចែងនៅក្នុងមាត្រា២៣ ស្តីពីវិធានការទាំងអស់ដែលត្រូវបានអនុវត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃស្ថានភាព ហើយគណៈកម្មាធិការអាចផ្តល់ជាអនុសាសន៍សមស្រប ។

## មាត្រា ៩ - ការចែករំលែកព័ត៌មាន និងតម្លាភាព

រដ្ឋភាគីទាំងអស់:

(ក) ផ្តល់រៀងរាល់បួនឆ្នាំម្តងនៅក្នុងរបាយការណ៍ជូនអង្គការយូណេស្កូ នូវព័ត៌មានសមស្របស្តីពីវិធានកាដែលត្រូវបានអនុវត្តដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ នៅលើដែនដីរបស់ខ្លួន និងនៅលើឆាកអន្តរជាតិ;

(ខ) ចាត់តាំងផ្នែកទំនាក់ទំនងមួយទទួលបន្ទុកចែករំលែកព័ត៌មានដែលពាក់ព័ន្ធនឹងអនុសញ្ញានេះ;

(គ) ចែករំលែក និងផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

## មាត្រា ១០ - ការអប់រំ និងចំណាប់អារម្មណ៍របស់សាធារណជន

រដ្ឋភាគីទាំងអស់ ៖

(ក) បង្កលក្ខណៈងាយស្រួល និងអភិវឌ្ឍការយល់ដឹងពីសារៈសំខាន់នៃការការពារ និងលើកស្ទួយវិញ្ញត្តិវប្បធម៌ ជាពិសេសតាមរយៈកម្មវិធីអប់រំ និងធ្វើឲ្យសាធារណជនមានចំណាប់អារម្មណ៍កាន់តែខ្លាំងក្លាឡើង;

(ខ) សហប្រតិបត្តិការជាមួយរដ្ឋភាគីដទៃទៀត និងអង្គការអន្តរជាតិក៏ដូចជា អង្គការក្នុងតំបន់ ដើម្បីសម្រេចឲ្យបាននូវគោលដៅនៃមាត្រានេះ;

(គ) យកចិត្តទុកដាក់លើកទឹកចិត្តដល់គំនិតច្នៃប្រឌិតបង្កើតថ្មី និងពង្រឹងសមត្ថភាពផលិតកម្មតាមរយៈការបង្កើតឲ្យមានកម្មវិធីអប់រំ ការបណ្តុះបណ្តាល និងការផ្លាស់ប្តូរនៅក្នុងវិស័យឧស្សាហកម្មវប្បធម៌។ វិធានការ ទាំងនេះគប្បីត្រូវអនុវត្តធ្វើយ៉ាងណាកុំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ទម្រង់ផលិតកម្មជាលក្ខណៈប្រពៃណី ។

## មាត្រា ១១ - ការចូលរួមរបស់សង្គមស៊ីវិល

រដ្ឋភាគីទាំងអស់ទទួលស្គាល់តួនាទីជាមូលដ្ឋានរបស់សង្គមស៊ីវិល នៅក្នុងការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។ រដ្ឋភាគីទាំងអស់ត្រូវលើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងសកម្មរបស់សង្គមស៊ីវិលដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឲ្យបានតាមគោលដៅនៃអនុសញ្ញានេះ ។

## មាត្រា ១២ - ការលើកស្ទួយកិច្ចសហប្រតិបត្តិការអន្តរជាតិ

រដ្ឋភាគីទាំងអស់ត្រូវខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្រិតតំបន់ និងអន្តរជាតិ ដើម្បីបង្កើតល័ក្ខខ័ណ្ឌសមស្របដល់ការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដោយយកចិត្តទុកដាក់ជាពិសេសដល់ស្ថានភាពដូចមានចែងនៅក្នុងមាត្រា ៨ និងមាត្រា ១៧ ក្នុងគោលដៅ:

(ក) សំរួលកិច្ចទំនាក់ទំនងរវាងរដ្ឋភាគីនីមួយៗស្តីពីគោលនយោបាយវប្បធម៌;

(ខ) ពង្រឹងសមត្ថភាពជាយុទ្ធសាស្ត្រ និងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈនៅក្នុងស្ថាប័នវប្បធម៌សាធារណៈ អាស្រ័យដោយការផ្លាស់ប្តូរវប្បធម៌តាមលក្ខណៈវិជ្ជាជីវៈ និងជាអន្តរជាតិ ព្រមទាំងការចែករំលែកនូវការអនុវត្តន៍ដ៏ល្អប្រសើរបំផុត;

(គ) ពង្រឹងភាពជាដៃគូជាមួយសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន និងរវាងអង្គភាពទាំងនេះ ដើម្បីបង្កលក្ខណៈងាយស្រួល និងលើកស្ទួយ ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌;

(ឃ) លើកស្ទួយការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងជំរុញភាពជាដៃគូ ដើម្បីពង្រឹងការចែករំលែកព័ត៌មាន និងការយល់ដឹងផ្នែកវប្បធម៌ និងដើម្បីបង្កលក្ខណៈងាយស្រួលដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌;

(ង) ជំរុញឲ្យមានការចុះកិច្ចព្រមព្រៀងសហផលិតកម្ម និងសហចែកចាយ ។

## មាត្រា ១៣ - សមាហរណកម្មវប្បធម៌ទៅក្នុងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

រដ្ឋភាគីទាំងអស់ត្រូវប្រឹងប្រែងធ្វើសមាហរណកម្មវប្បធម៌ទៅក្នុងគោលនយោបាយអភិវឌ្ឍន៏របស់ខ្លួននៅគ្រប់លំដាប់ថ្នាក់ ដើម្បីបង្កើតល័ក្ខខ័ណ្ឌសមស្របដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងនៅក្នុងក្របខ័ណ្ឌនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ទិដ្ឋភាពនានាពាក់ព័ន្ធនឹងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

## មាត្រា ១៤ - កិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍

រដ្ឋភាគីទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការគាំទ្រកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ ដោយឡែកពាក់ព័ន្ធនឹងតម្រូវការពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍន៏ សំដៅសម្រួលដល់ការលេចឡើងនូវវិស័យវប្បធម៌ដ៏រស់រវើកក្នុងចំណោមវិស័យដទៃទៀត តាមរយៈមធ្យោបាយដូចខាងក្រោម:

(ក) ការពង្រឹងឧស្សាហកម្មវប្បធម៌របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍:

(១) ដោយបង្កើត និងពង្រឹងសមត្ថភាពផលិត និងសមត្ថភាពចែកចាយវប្បធម៌ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍;

(២) ដោយជួយសម្រួលលការបញ្ច្រាបចូលបានយ៉ាងទូលំទូលាយនូវសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ទៅក្នុងទីផ្សារពិភពលោក និងទៅក្នុងបណ្តាញចែកចាយជាអន្តរជាតិ;

(៣) ដោយអនុញ្ញាតឲ្យមានការលេចឡើងនូវទីផ្សារក្នុងស្រុក និងថ្នាក់តំបន់ជាលក្ខណៈចីរភាព;

(៤) ដោយអនុម័តទទួលយកវិធានការសមស្របតាមដែលអាចធ្វើទៅបាន នៅក្នុងប្រទេសអភិវឌ្ឍន៍ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការបញ្ច្រាបចូលទៅក្នុងដែនដីរបស់ខ្លួននូវសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌របស់ប្រទេសកំពុងអភិវឌ្ឍន៍;

(៥) ដោយគាំទ្រការងារច្នៃប្រឌិត បង្កើតថ្មី និងដោយបង្កលក្ខណៈងាយស្រួលដល់ការបំលាស់ទីរបស់សិល្បករនៃប្រទេសកំពុងអភិវឌ្ឍន៍ តាមដែលអាចធ្វើទៅបាន;

(៦) ដោយជំរុញកិច្ចប្រតិបត្តិការសមស្របរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅក្នុងវិស័យតន្ត្រី និងវិស័យភាពយន្ត;

(ខ) ការពង្រឹងសមត្ថភាព តាមរយៈការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងកោសល្យវិច័យ ព្រមទាំងការបណ្តុះ-បណ្តាលធនធានមនុស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងវិស័យសាធារណៈ និងឯកជន ពាក់ព័ន្ធជាពិសេសនឹងសមត្ថភាពជាយុទ្ធសាស្ត្រ និងសមត្ថភាពគ្រប់គ្រងតាមរយៈការរៀបចំតាក់តែង និងការអនុវត្តគោលនយោបាយការលើកស្ទួយ និងការចែកចាយវិញ្ញត្តិវប្បធម៌ ការអភិវឌ្ឍន៍សហគ្រាសខ្នាតមធ្យម ខ្នាតតូច និងមីក្រូសហគ្រាស ការប្រើសប្រាស់បច្ចេកវិទ្យា ព្រមទាំងការអភិវឌ្ឍន៍ និងការផ្ទេរសមត្ថភាព;

(គ) ការផ្ទេរបច្ចេកវិទ្យា និងចំណេះធ្វើតាមរយៈការបង្កើតវិធានការលើកទឹកចិត្តសមស្រប ជាពិសេសនៅក្នុងវិស័យឧស្សាហកម្ម និងសហគ្រាសវប្បធម៌;

(ឃ) ការគាំទ្រផ្នែកហិរញ្ញវត្ថុ តាមមធ្យោបាយៈ

(១) បង្កើតមូលនិធិអន្តរជាតិសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ ដូចមានចែងនៅក្នុងមាត្រា ១៨;

(២) ផ្តល់ជំនួយសាធារណៈដល់ការអភិវឌ្ឍន៍ ទៅតាមតម្រូវការ រួមទាំងជំនួយបច្ចេកទេសសម្រាប់ជំរុញ និងគាំទ្រគំនិតច្នៃប្រឌិតបង្កើតថ្មី;

(៣) ទម្រង់ផ្សេងៗទៀតនៃជំនួយហិរញ្ញវត្ថុ ដូចជាការខ្ចីប្រាក់មានអត្រាការប្រាក់ទាប ឧបត្ថម្ភកធន និងយន្តការផ្តល់ហិរញ្ញប្បទានដទៃទៀត ។

## មាត្រា ១៥ - បែបបទនៃកិច្ចសហប្រតិបត្តិការ

រដ្ឋភាគីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍ភាពជាដៃគូ រវាងវិស័យសាធារណៈ និងវិស័យឯកជន និងអង្គការមានគោលដៅមិនស្វែងរកប្រាក់ចំណេញ និងក្នុងរង្វង់ដែនដីរបស់ខ្លួន ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍ សំដៅពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។ ជាកិច្ចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍ ភាពជាដៃគូប្រកបដោយលក្ខណៈច្នៃប្រឌិតទាំងនេះនឹងសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធនធានមនុស្ស និងគោលនយោបាយ ព្រមទាំងទៅលើការផ្លាស់ប្តូរសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ។

## មាត្រា ១៦ - ភាពអនុគ្រោះចំពោះប្រទេសកំពុងអភិវឌ្ឍ

ប្រទេសអភិវឌ្ឍបង្កលក្ខណៈងាយស្រួលដល់ការផ្លាស់ប្តូរវប្បធម៌ ជាមួយនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍ ដោយផ្តល់នូវភាពអនុគ្រោះដល់សិល្បករ អ្នកវិជ្ជាជីវៈ និងអ្នកអនុវត្តខាងវប្បធម៌ដទៃទៀត ព្រមទាំងដល់ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌របស់ប្រទេសកំពុងអភិវឌ្ឍ តាមរយៈក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌគតិយុត្តសមស្រប ។

## មាត្រា ១៧ - កិច្ចសហប្រតិបត្តិការអន្តរជាតិស្ថិតក្នុងស្ថានភាពគំរាមកំហែងធ្ងន់ធ្ងរប្រឆាំងនឹងវិញ្ញត្តិវប្បធម៌

រដ្ឋភាគីទាំងអស់ ធ្វើកិច្ចសហប្រតិបត្តិការដើម្បីជួយគ្នាទៅវិញទៅមកដោយយកចិត្តទុកដាក់ ជាពិសេសទៅលើប្រទេសកំពុងអភិវឌ្ឍនៅក្នុងស្ថានភាពដូចមានចែងក្នុងមាត្រា ៨ ។

## មាត្រា ១៨ - មូលនិធិអន្តរជាតិសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌

១- ត្រូវបានបង្កើតមូលនិធិអន្តរជាតិមួយសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ ដែលតទៅនេះត្រូវបានហៅកាត់ថា "មូលនិធិ" ។

២- មូលនិធិនេះ គឺជាមូលនិធិដាក់បញ្ញើដោយអនុលោមទៅតាមបទបញ្ញាហិរញ្ញវត្ថុរបស់អង្គការយូណេស្កូ ។

៣- ធនធានមូលនិធិមានប្រភពមកពីៈ

(ក) ប្រាក់វិភាគទានស្ម័គ្រចិត្តផ្តល់ដោយរដ្ឋភាគីទាំងឡាយ;

(ខ) មូលនិធិដែលផ្តល់ឲ្យក្នុងគោលបំណងនេះដោយសន្និសីទកំពូលរបស់អង្គការយូណេស្កូ;

(គ) ប្រាក់បរិច្ចាគ ប្រាក់អំណោយ ឬអច្ច័យទានដែលអាចត្រូវបានផ្តល់ឲ្យដោយរដ្ឋដទៃទៀត ដោយអង្គការនានា និងដោយកម្មវិធីរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ អង្គការក្នុងតំបន់ ឬអង្គការអន្តរជាតិ និងអង្គការសាធារណៈ ឬអង្គការឯកជន ឬបុគ្គលជាឯកជន;

(ឃ) ការប្រាក់ទាំងអស់ដែលជាប់ជំពាក់ទៅនឹងធនធាននៃ "មូលនិធិ";

(ង) ប្រាក់ចំណូលបានមកពីការរៃអង្គាសនិងប្រាក់កម្រៃបានមកពីការសំដែងនានាដែលរៀប ចំឡើងដើម្បីប្រយោជន៍នៃមូលនិធិ;

(ច) ធនធានដទៃទៀតទាំងអស់ដែលអនុញ្ញាតដោយបទបញ្ញារបស់មូលនិធិ ។

៤- ការប្រើប្រាស់ធនធានមូលនិធិត្រូវសម្រេចដោយគណៈកម្មាធិការអន្តររដ្ឋាភិបាល ដោយផ្អែកទៅលើការតម្រង់ទិសពីសន្និសីទរបស់រដ្ឋភាគី ដូចមានចែងក្នុងមាត្រា ២២ ។

៥- គណៈកម្មាធិការអន្តររដ្ឋាភិបាលអាចយល់ព្រមទទួលយកវិភាគទាន និងជំនួយឧបត្ថម្ភក្រោមទម្រង់ដទៃទៀតក្នុងគោលបំណងទូទៅ ឬពិសេសដែលពាក់ព័ន្ធនឹងគម្រោងជាក់លាក់ ឲ្យតែគម្រោងទាំងនេះត្រូវបានអនុម័តដោយគណៈកម្មាធិការនេះ ។

៦- ការផ្តល់វិភាគទានផ្សេងៗដល់មូលនិធិមិនអាចភ្ជាប់ទៅនឹងល័ក្ខខ័ណ្ឌនយោបាយ សេដ្ឋកិច្ច ឬរូបភាពផ្សេងៗទៀត

ដែលមានលក្ខណៈវិសមិតភាពនឹងគោលដៅរបស់អនុសញ្ញានេះឡើយ ។

៧- រដ្ឋភាគីទាំងឡាយត្រូវយកចិត្តទុកដាក់ផ្តល់វិភាគទានស្ម័គ្រចិត្តជាទៀងទាត់ ដើម្បីឲ្យអនុសញ្ញានេះអាចអនុវត្តបានសម្រេច ។

## មាត្រា ១៩ - ការផ្លាស់ប្តូរ ការវិភាគ និងការផ្សព្វផ្សាយព័ត៌មាន

១- រដ្ឋភាគីទាំងអស់យល់ព្រមផ្លាស់ប្តូរព័ត៌មាន និងកោសល្យវិច័យ ពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ និងស្ថិតិស្តីពីភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ព្រមទាំងការអនុវត្តដ៏ល្អប្រសើរ ដើម្បីការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌

២- អង្គការយូណេស្កូបង្កលក្ខណៈងាយស្រួលដល់ការប្រមូល ការវិភាគ និងការផ្សព្វផ្សាយព័ត៌មាន ស្ថិតិ និងការអនុវត្តដ៏ល្អប្រសើរទាំងអស់ក្នុងវិស័យនេះ តាមរយៈយន្តការដែលមានស្រាប់នៅក្នុងលេខាធិការដ្ឋាន ។

៣- ម្យ៉ាងវិញទៀត អង្គការយូណេស្កូបង្កើត និងធ្វើបច្ចុប្បន្នភាពធនាគារទិន្នន័យពាក់ព័ន្ធនឹងវិស័យផ្សេងៗ និងអង្គការរដ្ឋាភិបាល អង្គការឯកជន និងអង្គការមានគោលដៅមិនស្វែងរកប្រាក់ចំណេញនានា ដែលធ្វើសកម្មភាពនៅក្នុងវិស័យនៃវិញ្ញត្តិវប្បធម៌ ។

៤- ដើម្បីសំរួលដល់ការប្រមូលទិន្នន័យផ្សេងៗ អង្គការយូណេស្កូផ្តោតការយកចិត្តទុកដាក់ជាពិសេសមួយលើការពង្រឹងសមត្ថភាព និងកោសល្យវិច័យរបស់រដ្ឋភាគីទាំងអស់ដែលលើកសំណើសុំជំនួយពាក់ព័ន្ធនឹងបញ្ហានេះ ។

៥- ការប្រមូលព័ត៌មានដែលបានកំណត់នៅក្នុងមាត្រានេះ បំពេញបន្ថែមព័ត៌មានដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃមាត្រា ៩ ។

# ៥. ទំនាក់ទំនងជាមួយលិខិតូបករណ៍ដទៃទៀត

## មាត្រា ២០ - ទំនាក់ទំនងជាមួយលិខិតូបករណ៍ដទៃទៀតៈ ការគាំទ្រគ្នាទៅវិញទៅមក ការបំពេញបន្ថែម និងការមិនចំណុះគ្នា

១- រដ្ឋភាគីទាំងអស់ទទួលស្គាល់ថាខ្លួនត្រូវបំពេញដោយសុទ្ធចិត្តនូវកាតព្វកិច្ចរបស់ពួកគេ យោងតាមអនុសញ្ញានេះ និងសន្ធិសញ្ញាដទៃទៀតទាំងអស់ដែលខ្លួនជាភាគី ។ ដូច្នេះមិនត្រូវដាក់អនុសញ្ញានេះឲ្យនៅចំណុះនឹងសន្ធិសញ្ញាដទៃទៀតឡើយ

(ក) រដ្ឋភាគីទាំងអស់លើកទឹកចិត្តដល់ការគាំទ្រគ្នាទៅវិញទៅមករវាងអនុសញ្ញានេះ និងសន្ធិសញ្ញាដទៃទៀតដែលខ្លួនជាភាគី ហើយ;

(ខ) នៅពេលដែលរដ្ឋភាគីបកស្រាយ និងអនុវត្តសន្ធិសញ្ញាដទៃទៀតដែលខ្លួនជាភាគី ឬនៅពេលដែលរដ្ឋភាគីត្រូវបានចងភ្ជាប់ដោយកាតព្វកិច្ចអន្តរជាតិផ្សេងទៀត រដ្ឋភាគីទាំងឡាយនេះ ត្រូវយកចិត្តទុកដាក់ទៅលើបទប្បញ្ញត្តិច្បាស់លាស់ នៃអនុសញ្ញានេះ។

២- គ្មានចំណុចណាមួយនៅក្នុងអនុសញ្ញានេះអាចត្រូវបានបកស្រាយថាជាការកែប្រែសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគី ឲ្យស្របតាមសន្ធិសញ្ញាដទៃទៀតដែលខ្លួនជាភាគីឡើយ ។

## មាត្រា ២១ - ការព្រមព្រៀង និងការសម្របសម្រួលអន្តរជាតិ

រដ្ឋភាគីទាំងអស់សន្យាលើកស្ទួយគោលដៅ និងគោលការណ៍នៃអនុសញ្ញានេះ នៅក្នុងវេទិកាអន្តរជាតិដទៃទៀត ។ ដើម្បីសម្រេចគោលដៅនេះ បណ្តារដ្ឋភាគីធ្វើការពិគ្រោះយោបល់គ្នា ប្រសិនបើអាចធ្វើទៅបាន ដោយប្រកាន់ភ្ជាប់នូវស្មារតីនៃគោលដៅ និងគោលការណ៍ទាំងនេះ ។

# ៦. អង្គការនៃអនុសញ្ញា

## មាត្រា ២២ - សន្និសីទរដ្ឋភាគី

១- ត្រូវបានបង្កើតសន្និសីទរដ្ឋភាគីមួយ ដែលជាអង្គការពេញអង្គ និងកំពូលនៃអនុសញ្ញានេះ ។

២- សន្និសីទរដ្ឋភាគីធ្វើការប្រជុំជាសម័យប្រជុំសាមញ្ញរៀងរាល់ពីរឆ្នាំម្តង តាមដែលអាចធ្វើទៅបាន នៅក្នុងក្របខ័ណ្ឌនៃសន្និសីទកំពូលរបស់អង្គការយូណេស្កូ។សន្និសីទរដ្ឋភាគីអាចធ្វើការប្រជុំជាសម័យប្រជុំវិសាមញ្ញបានប្រសិនបើសន្និសីទធ្វើការសម្រេចដូច្នេះ ឬប្រសិនបើមានសំណើរផ្ញើទៅគណៈកម្មាធិការអន្តររដ្ឋាភិបាល ដោយរដ្ឋភាគីចំនួនយ៉ាងហោចណាស់មួយភាគបី ។

៣- សន្និសីទរដ្ឋភាគីធ្វើការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៤- សន្និសីទរដ្ឋភាគីមានមុខងារដូចតទៅ:

(ក) បោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាល;

(ខ) ទទួល និងពិនិត្យរបាយការណ៍របស់បណ្តារដ្ឋភាគីនៃអនុសញ្ញានេះ ដែលបានផ្ញើទៅដោយគណៈកម្មាធិការ-អន្តររដ្ឋាភិបាល;

(គ) អនុម័តសេចក្តីណែនាំប្រតិបត្តិដែលរៀបចំឡើងដោយគណៈកម្មាធិការអន្តររដ្ឋាភិបាល តាមសំណើរបស់ខ្លួន;

(ឃ) ចាត់វាល់វិធានការដែលខ្លួនយល់ថាមានការចាំបាច់ ដើម្បីលើកស្ទួយគោលដៅនៃអនុសញ្ញានេះ ។

## មាត្រា ២៣ - គណៈកម្មាធិការអន្តររដ្ឋាភិបាល

១- ត្រូវបានបង្កើតនៅក្នុងអង្គការយូណេស្កូនូវគណៈកម្មាធិការអន្តររដ្ឋាភិបាលមួយ ដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដែលតទៅនេះត្រូវបានហៅថា "គណៈកម្មាធិការអន្តររដ្ឋាភិបាល" ។ គណៈកម្មាធិការនេះមានសមាសភាពតំណាងមកពីរដ្ឋចំនួន ១៨ ជាភាគីនៃអនុសញ្ញានេះ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិ៤ឆ្នាំ ដោយសន្និសីទរដ្ឋភាគី ចាប់តាំងពីពេលដែលអនុសញ្ញានេះចូលជាធរមាន អនុលោមតាមមាត្រា ២៩ ។

២- គណៈកម្មាធិការអន្តររដ្ឋាភិបាលធ្វើការប្រជុំម្តងក្នុង១ឆ្នាំ ។

៣- គណៈកម្មាធិការអន្តររដ្ឋាភិបាលដំណើរការក្រោមអំណាចនៃការគ្រប់គ្រង និងស្របតាមសេចក្តីណែនាំនៃសន្និសីទរដ្ឋភាគី ហើយត្រូវរាយការណ៍ជូនសន្និសីទនេះ ។

៤- គណៈកម្មាធិការអន្តររដ្ឋាភិបាលនឹងមានសមាជិកកើនឡើងដល់ចំនួន ២៤ នៅពេលដែលចំនួនរដ្ឋភាគីនៃអនុសញ្ញានេះនឹងកើនឡើងរហូតដល់ ៥០ រដ្ឋ ។

៥- ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាលត្រូវធ្វើឡើង ដោយផ្អែកទៅលើគោលការណ៍នៃការបែងចែកទីតាំងភូមិសាស្ត្រប្រកបដោយសមធម៌ និងផ្លាស់ប្តូរវេនគ្នា ។

៦- ដោយមិនគិតដល់ភារកិច្ចផ្សេងៗទៀតដែលអនុសញ្ញានេះប្រគល់ទៅឲ្យគណៈកម្មាធិការ មុខងាររបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលមានដូចតទៅ:

(ក) លើកស្ទួយគោលដៅនៃអនុសញ្ញានេះ លើកទឹកចិត្ត និងធ្វើការតាមដានការអនុវត្តអនុសញ្ញានេះ;

(ខ) រៀបចំ និងដាក់ជូនសន្និសីទរដ្ឋភាគីដើម្បីអនុម័ត ទៅតាមសំណើរបស់សន្និសីទនូវសេចក្តីណែនាំប្រតិបត្តិពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ;

(គ) ផ្ញើជូនសន្និសីទរដ្ឋភាគីនូវរបាយការណ៍របស់រដ្ឋភាគីអនុសញ្ញា រួមមានការវាយតម្លៃរបស់គណៈកម្មាធិការ និងខ្លឹមសារសង្ខេបនៃរបាយការណ៍ទាំងនោះផង;

(ឃ) ផ្តល់អនុសាសន៍សមស្រប នៅក្នុងស្ថានភាពដែលរដ្ឋភាគីនៃអនុសញ្ញាបានទាញចំណាប់អារម្មណ៍របស់គណៈកម្មាធិការ ស្របតាមបទប្បញ្ញត្តិច្បាស់លាស់នៃអនុសញ្ញា ជាពិសេសមាត្រា ៨;

(ង) រៀបចំបង្កើតនីតិវិធី និងយន្តការពិគ្រោះយោបល់ផ្សេងៗទៀត ដើម្បីលើកស្ទួយគោលដៅ និងគោលការណ៍នៃអនុសញ្ញានេះ នៅក្នុងវេទិកាអន្តរជាតិដទៃទៀត;

(ច) បំពេញរាល់កិច្ចការទាំងអស់ដែលសន្និសីទរដ្ឋភាគីអាចប្រគល់ឲ្យ ។

៧- យោងទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន គណៈកម្មាធិការអន្តររដ្ឋាភិបាលអាចកោះអញ្ជើញអង្គការសាធារណៈ ឬអង្គការឯកជន ឬរូបវន្តបុគ្គលនៅគ្រប់ពេលទាំងអស់ ឲ្យចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិគ្រោះយោបល់ទៅលើបញ្ហាពិសេសដោយឡែកផ្សេងៗ ។

៨- គណៈកម្មាធិការអន្តររដ្ឋាភិបាលធ្វើការតាក់តែងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ហើយដាក់ជូនសន្និសីទរដ្ឋភាគីធ្វើការអនុម័ត ។

### មាត្រា ២៤ - លេខាធិការដ្ឋានអង្គការយូណេស្កូ

១- អង្គការនៃអនុសញ្ញានេះមានជំនួយពីលេខាធិការដ្ឋានអង្គការយូណេស្កូ ។

២- លេខាធិការដ្ឋានរៀបចំឯកសាររបស់សន្និសីទរដ្ឋភាគី និងឯកសាររបស់គណៈកម្មាធិការអន្តររដ្ឋាភិបាល ព្រមទាំងសេចក្តី ព្រាងរបៀបវារៈនៃកិច្ចប្រជុំ ជួយដល់ការអនុវត្តនៃសេចក្តីសម្រេចរបស់ពួកគេ និងធ្វើរបាយការណ៍ពីការអនុវត្តនេះ។

## ៧. អវសានប្បញ្ញត្តិ

### មាត្រា ២៥ - ការដោះស្រាយវិវាទ

១- ក្នុងករណីមានវិវាទកើតឡើងរវាងរដ្ឋភាគីនៃអនុសញ្ញានេះ ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញា រដ្ឋភាគីត្រូវស្វែងរកដំណោះស្រាយមួយតាមរយៈការចរចា ។

២- ប្រសិនបើរដ្ឋភាគីពាក់ព័ន្ធទាំងអស់មិនអាចឈានទៅដល់ការព្រមព្រៀងតាមរយៈការចរចាបានទេ ពួកគេអាចព្រមព្រៀងគ្នាស្វែងរកអន្តរាគមន៍ផ្សះផ្សាពីខាងក្រៅ ឬស្នើសុំឲ្យតតិយជនជួយសម្រុះសម្រួល ។

៣- ប្រសិនបើគ្មានអន្តរាគមន៍ផ្សះផ្សា ឬសម្រុះសម្រួលទេ ឬប្រសិនបើវិវាទមិនអាចដោះស្រាយតាមរយៈការចរចា

អន្តរាគមន៍ផ្សះផ្សា ឬសម្រុះសម្រួលបានទេ រដ្ឋភាគីមួយអាចស្វែងរកជំនួយផ្សះផ្សា ដោយអនុលោមទៅតាមនីតិវិធីដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញានេះ ។ រដ្ឋភាគីទាំងអស់ត្រូវតែពិនិត្យដោយសុទ្ធចិត្តនូវសំណើដំណោះស្រាយវិវាទ ដែលលើកឡើងដោយគណៈកម្មធិការផ្សះផ្សា ។

៤- នៅពេលឲ្យសច្ចាប័នយល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក រដ្ឋភាគីនីមួយៗអាចប្រកាសថា ខ្លួនមិនទទួលស្គាល់នីតិវិធីផ្សះផ្សាដែលមានចែងខាងលើទេ ។ រដ្ឋភាគីទាំងឡាយណាដែលបានធ្វើសេចក្តីប្រកាសបែបនេះ រួចហើយអាចដកសេចក្តីប្រកាសនោះវិញនៅគ្រប់ពេល ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយកអង្គការយូណេស្កូ ។

## មាត្រា ២៦ - ការឲ្យសច្ចាប័ន ការយល់ព្រមទទួលយក ការឯកភាពចូលជាសមាជិក ដោយរដ្ឋជាសមាជិក

១- អនុសញ្ញានេះត្រូវបានដាក់ជូនរដ្ឋជាសមាជិករបស់អង្គការយូណេស្កូ ដើម្បីឲ្យសច្ចាប័នយល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ដោយអនុលោមទៅតាមនីតិវិធីរដ្ឋធម្មនុញ្ញរបស់រដ្ឋទាំងនោះរៀងៗខ្លួន ។

២- លិខិតូបករណ៍ធ្វើសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ត្រូវបានតំកល់ទុកនៅអគ្គនាយកអង្គការយូណេស្កូ ។

## មាត្រា ២៧ - ការចូលជាសមាជិក

១- អនុសញ្ញានេះបើកចំហដល់បណ្តារដ្ឋទាំងឡាយ ដែលមិនមែនជាសមាជិករបស់អង្គការយូណេស្កូ ឲ្យចូលជាសមាជិក ប៉ុន្តែរដ្ឋទាំងនោះ ត្រូវតែជាសមាជិករបស់អង្គការសហប្រជាជាតិ ឬជាសមាជិកនៃស្ថាប័នជំនាញមួយ ក្នុងចំណោមស្ថាប័នជំនាញផ្សេងៗរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានអញ្ជើញឲ្យចូលជាសមាជិកនៃអនុសញ្ញានេះដោយសន្និសីទកំពូលរបស់អង្គការ ។

២- អនុសញ្ញានេះក៏បើកចំហឲ្យចូលជាសមាជិកផងដែរ ចំពោះដែនដីដែលមានស្វ័យភាពផ្ទៃក្នុងពេញលេញ ដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់មានឯករាជ្យភាពពេញលេញ អនុលោមតាមសេចក្តីសម្រេចលេខ ១៥១៤ (XV) នៃមហាសន្និបាត និងមានសមត្ថកិច្ចចំពោះវិស័យដែលអនុសញ្ញានេះយកចិត្តទុកដាក់លើ រួមទាំងសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងវិស័យទាំងនេះផង ។

៣- បទប្បញ្ញត្តិខាងក្រោមនេះអនុវត្តទៅលើអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់:

(ក) អនុសញ្ញានេះក៏បើកចំហឲ្យចូលជាសមាជិកផងដែរ ចំពោះអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ទាំងឡាយណាដែលចងកាតព្វកិច្ចពេញលេញដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដូចគ្នានឹងបណ្តារដ្ឋភាគីផងដែរ លើកលែងតែអញ្ញត្រកម្មដែលមានចែងក្នុងកថាខ័ណ្ឌនានាខាងក្រោម;

(ខ) នៅពេលរដ្ឋមួយ ឬច្រើនដែលជាសមាជិកអង្គការបែបនេះ ក៏ជាភាគីនៃអនុសញ្ញានេះដែរអង្គការ និងរដ្ឋជាសមាជិកទាំងនេះ បានព្រមព្រៀងទៅតាមការទទួលខុសត្រូវរបស់ខ្លួន ក្នុងការអនុវត្តកាតព្វកិច្ចរបស់ពួកគេស្របតាមអនុសញ្ញានេះ ។ ការបែងចែកការទទួលខុសត្រូវនេះមានអានុភាពនៅពេលបញ្ចប់នីតិវិធីនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដូចមានរៀបរាប់ក្នុងវាក្យខ័ណ្ឌ (ខ) ។ អង្គការ និងរដ្ឋជាសមាជិកមិនមាននីតិសម្បទាក្នុងការអនុវត្តរួមគ្នានូវសិទ្ធិ ដែលកើតចេញពីអនុសញ្ញានេះឡើយ ។ ម្យ៉ាងវិញទៀតនៅក្នុងវិស័យដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មានចំនួនសំឡេងឆ្នោតស្មើ

នឹង ចំនួនរដ្ឋជាសមាជិកដែលជាភាគីនៃអនុសញ្ញានេះ ដើម្បីអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន ។ អង្គការទាំងនេះ មិនអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនឡើយ ប្រសិនបើរដ្ឋជាសមាជិកនៃអង្គការនេះអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន និងផ្ទុយមកវិញ;

(គ) អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ និងរដ្ឋជាសមាជិករបស់ខ្លួនដែលបានព្រមព្រៀងឲ្យមានការបែងចែក ការទទួលខុសត្រូវដូចដែលបានចែងនៅក្នុងវាក្យខ័ណ្ឌ (ខ) ផ្តល់ដំណឹងដល់ភាគីទាំងអស់ពីការបែងចែកនេះ តាមវិធីដូចខាងក្រោមៈ

(១)- នៅក្នុងលិខិតូបករណ៍ចូលជាសមាជិក អង្គការនេះបញ្ជាក់យ៉ាងច្បាស់លាស់ពីការបែងចែកការទទួលខុស ត្រូវពាក់ព័ន្ធនឹងបញ្ហាដែលគ្រប់គ្រងដោយអនុសញ្ញា;

(២)- ក្នុងករណីមានការកែប្រែការទទួលខុសត្រូវរៀងៗខ្លួននៅពេលក្រោយ អង្គការសមាហរណកម្មសេដ្ឋកិច្ច តំបន់ ត្រូវផ្តល់ដំណឹងដល់អ្នកតំកល់ឯកសារ នូវរាល់សំណើកែប្រែការទទួលខុសត្រូវទាំងនេះ ។ រីឯអ្នក តំកល់ឯកសារវិញត្រូវជូនដំណឹងទៅភាគីទាំងអស់ពីការកែប្រែនេះ;

(ឃ) បណ្តារដ្ឋជាសមាជិកនៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ដែលក្លាយទៅជាភាគីនៃអនុសញ្ញានេះ ត្រូវចាត់ទុកថា ខ្លួននៅតែមានសមត្ថកិច្ចក្នុងគ្រប់វិស័យដែលមិនមែនជាកម្មវត្ថុនៃការផ្ទេរសមត្ថកិច្ចទៅឲ្យអង្គការ ដែលត្រូវបានប្រកាស ឬជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឲ្យអ្នកតំកល់ឯកសារ;

(ង) ពាក្យថា "អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់" សំដៅដល់អង្គការមួយដែលបង្កើតឡើងដោយបណ្តារដ្ឋអធិ បតេយ្យជាសមាជិករបស់អង្គការសហប្រជាជាតិ ឬស្ថាប័នជំនាញមួយក្នុងចំណោមស្ថាប័នជំនាញទាំងឡាយ របស់អង្គការសហប្រជាជាតិ ដែលរដ្ឋទាំងនេះបានផ្ទេរសមត្ថកិច្ចរបស់ខ្លួនទៅក្នុងវិស័យដែលគ្រប់គ្រងដោយ អនុសញ្ញានេះហើយដែលត្រូវបានអនុញ្ញាតយ៉ាងត្រឹមត្រូវឲ្យក្លាយទៅជាភាគីយោងតាមនីតិវិធីផ្ទៃក្នុង ។

៤- លិខិតូបករណ៍ចូលជាសមាជិកត្រូវបានតំកល់ទុកនៅអគ្គនាយកអង្គការយូណេស្កូ ។

## មាត្រា ២៨ - កន្លែងទាក់ទងព័ត៌មាន

នៅពេលដែលបានក្លាយជាភាគីនៃអនុសញ្ញានេះ ភាគីនីមួយៗត្រូវកំណត់ពីកន្លែងទាក់ទងព័ត៌មាន ដូចដែលមាន ចែងនៅក្នុងមាត្រា ៩ ។

## មាត្រា ២៩ - ការចូលជាធរមាន

១- អនុសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេលបីខែ ក្រោយកាលបរិច្ឆេទនៃការតំកល់លិខិតូបករណ៍ឲ្យសច្ចាប័ន យល់ព្រមទទួលយកឯកភាព ឬចូលជាសមាជិកលើកទី៣០ ប៉ុន្តែការធ្វើបែបនេះ គឺចំពោះតែរដ្ឋ ឬអង្គការសមាហរណកម្ម សេដ្ឋកិច្ចតំបន់ ដែលបានតំកល់លិខិតូបករណ៍ធ្វើសច្ចាប័នយល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិករបស់ខ្លួនតាម កាលបរិច្ឆេទនោះឬមុនពេលនោះប៉ុណ្ណោះ ។ អនុសញ្ញានេះនឹងចូលជាធរមានសម្រាប់គ្រប់រដ្ឋភាគីដទៃទៀត ក្នុងរយៈពេល បីខែក្រោយពីបានតំកល់លិខិតូបករណ៍ឲ្យសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ។

២- ដើម្បីបំរើគោលដៅនៃមាត្រានេះ គ្មានលិខិតូបករណ៍ណាមួយ ដែលបានតំកល់ដោយអង្គការសមាហរណកម្មសេដ្ឋ-កិច្ចតំបន់មួយ ត្រូវបានចាត់ទុកថាមកបន្ថែមលើលិខិតូបករណ៍ ដែលរដ្ឋជាសមាជិកនៃអង្គការនេះបានតំកល់ទុករួចហើយ ឡើយ ។

## មាត្រា ៣០ - របបរដ្ឋធម្មនុញ្ញសហព័ន្ធ ឬមិនមែនរដ្ឋទោល

ដោយទទួលស្គាល់ថា កិច្ចព្រមព្រៀងអន្តរជាតិក៏ចងផងដែរនូវកាតព្វកិច្ចរដ្ឋភាគី ដោយមិនអាស្រ័យនឹងប្រព័ន្ធរដ្ឋធម្មនុញ្ញរបស់ខ្លួន រាល់បទប្បញ្ញត្តិខាងក្រោមនេះអនុវត្តន៍ចំពោះរដ្ឋភាគីណាដែលមានរបបរដ្ឋធម្មនុញ្ញសហព័ន្ធ ឬមិនមែនរដ្ឋទោលៈ

(ក) ពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តស្ថិតក្នុងសមត្ថកិច្ចនៃអំណាចនីតិបញ្ញត្តិសហព័ន្ធ ឬអំណាចនីតិបញ្ញត្តិកណ្តាល កាតព្វកិច្ចរបស់រដ្ឋាភិបាលសហព័ន្ធ ឬរដ្ឋាភិបាលកណ្តាល គឺដូចគ្នាទៅនឹងកាតព្វកិច្ចរបស់រដ្ឋភាគីដែលមិនមែនជារដ្ឋសហព័ន្ធដែរ;

(ខ) ពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តស្ថិតក្នុងសមត្ថកិច្ចនៃអង្គភាពប្រមូលផ្តុំនីមួយៗ ដូចជារដ្ឋតំបន់(កុងតេ) ខេត្ត ឬស្រុក(កង់តុង) ដែលមិនចាំបាច់ត្រូវចាត់វិធានការច្បាប់ស្របតាមរបបរដ្ឋ-ធម្មនុញ្ញសហព័ន្ធ ប្រសិនបើចាំបាច់ រដ្ឋាភិបាលសហព័ន្ធនឹងផ្តល់ដំណឹងពីបទប្បញ្ញត្តិទាំងនេះដល់អាជ្ញាធរមានសមត្ថកិច្ចនៃ អង្គភាពប្រមូលផ្តុំ ដូចជារដ្ឋ តំបន់ (កុងតេ) ខេត្ត ឬស្រុក(កង់តុង) ដោយមានយោបល់យល់ស្របដើម្បីធ្វើការអនុម័ត ។

## មាត្រា ៣១ - ការបដិសេធ

១- ភាគីនីមួយៗមានលទ្ធភាពបដិសេធអនុសញ្ញានេះ ។

២- ការបដិសេធត្រូវជូនដំណឹងតាមរយៈលិខិតូបករណ៍ជាលាយលក្ខណ៍អក្សរតំកល់ទុកនៅអគ្គនាយកអង្គការយូណេស្កូ។

៣- ការបដិសេធមានសុពលភាពក្នុងរយៈពេល១២ខែ ក្រោយពីបានទទួលលិខិតូបករណ៍បដិសេធ ។ ការបដិសេធនេះមិនកែប្រែកាតព្វកិច្ចហិរញ្ញវត្ថុដែលរដ្ឋភាគីបដិសេធត្រូវអនុវត្តរហូតដល់កាលបរិច្ឆេទនៃការដកខ្លួនចេញមានសុពលភាព ។

## មាត្រា ៣២ - មុខងាររបស់អ្នកតំកល់ឯកសារ

ក្នុងនាមជាអ្នកទទួលកំកល់ឯកសារនៃអនុសញ្ញានេះ អគ្គនាយកអង្គការយូណេស្កូត្រូវផ្តល់ព័ត៌មានទៅរដ្ឋជាសមាជិកអង្គការ រដ្ឋមិនមែនជាសមាជិក និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដូចមានចែងក្នុងមាត្រា ២៧ ព្រមទាំងអង្គការសហប្រជាជាតិ អំពីការតំកល់ទុករាល់លិខិតូបករណ៍សម្រាប់ផ្តល់សច្ចាប័នយល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិកដែលមានបញ្ជាក់ក្នុងមាត្រា ២៦ និង មាត្រា ២៧ និងពីការបដិសេធដែលមានចែងក្នុងមាត្រា ៣១ ។

## មាត្រា ៣៣ - វិសោធនកម្ម

១- រដ្ឋភាគីនីមួយៗ អាចស្នើសុំធ្វើវិសោធនកម្មអនុសញ្ញានេះ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរផ្ញើទៅអគ្គនាយក ។ អគ្គ-នាយកបញ្ជូនលិខិតនេះទៅគ្រប់រដ្ឋភាគីទាំងអស់ ។ ប្រសិនបើនៅក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនលិខិត រដ្ឋភាគីចំនួនយ៉ាងហោចណាស់ពាក់កណ្តាល បានផ្តល់ចម្លើយយល់ស្របនឹងសំណើនេះ អគ្គនាយកមានសិទ្ធិដាក់បង្ហាញ សំណើនេះសម្រាប់សម័យប្រជុំរបស់សន្និសីទរដ្ឋភាគីលើកក្រោយ ដើម្បីពិភាក្សា និងធ្វើការអនុម័តជាយថាហេតុ ។

២- វិសោធនកម្មត្រូវអនុម័តដោយសំឡេងភាគច្រើនពីរភាគបីនៃរដ្ឋភាគីមានវត្តមាន និងចូលរួមបោះឆ្នោត ។

៣- នៅពេលអនុម័តរួចហើយ វិសោធនកម្មអនុសញ្ញានេះត្រូវបញ្ជូនទៅរដ្ឋភាគីទាំងអស់ ដើម្បីឲ្យសច្ចាប័នយល់ព្រម ទទួលយក ឯកភាព ឬចូលជាសមាជិក ។

៤- ចំពោះភាគីដែលបានឲ្យសច្ចាប័ន យល់ព្រម ទទួលយក ឯកភាព ឬចូលជាសមាជិកវិសោធនកម្មអនុសញ្ញានេះចូលជា-ធរមានក្នុងរយៈពេលបីខែក្រោយពីបានតំកល់ទុកលិខិតូបករណ៍ដោយភាគីចំនួនពីរភាគបីដូចដែលមានចែងក្នុងកថាខ័ណ្ឌ ៣ នៃមាត្រានេះ ។ បន្ទាប់មកទៀត ចំពោះរដ្ឋភាគីនីមួយៗដែលឲ្យសច្ចាប័ន យល់ព្រម ទទួលយក ឯកភាព ឬចូលជាសមា-ជិកវិសោធនកម្មនេះចូលជាធរមានក្នុងរយៈពេលបីខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់ទុកលិខិតូបករណ៍ធ្វើសច្ចាប័ន យល់ព្រម ទទួលយក ឯកភាព ឬចូលជាសមាជិក ។

៥- នីតិវិធីដែលបានរៀបចំឡើងនៅក្នុងកថាខ័ណ្ឌ ៣ និងកថាខ័ណ្ឌ ៤ មិនអនុវត្តចំពោះវិសោធនកម្មមាត្រា ២៣ ពាក់ព័ន្ធនឹងចំនួនសមាជិកនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលឡើយ ។ វិសោធនកម្មទាំងនោះចូលជាធរមាននៅពេលផ្តល់ការអនុ-ម័តដោយរដ្ឋភាគីទាំងអស់ ។

៦- រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ក្នុងន័យនៃមាត្រា ២៧ ដែលក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះ បន្ទាប់ពីវិសោធនកម្មនេះចូលជាធរមាន អនុលោមទៅតាមកថាខ័ណ្ឌ ៤ នៃមាត្រានេះ ប្រសិនបើមិនមានការសំដែងចេតនាផ្សេងគ្នា ត្រូវបានចាត់ទុកថាជាៈ

(ក) រដ្ឋភាគីនៃអនុសញ្ញានេះដែលបានធ្វើវិសោធនកម្ម; និង

(ខ) រដ្ឋភាគីនៃអនុសញ្ញានេះដែលមិនបានធ្វើវិសោធនកម្ម ចំពោះគ្រប់ភាគីដែលមិនបានចងកាតព្វកិច្ចដោយវិសោធនកម្មទាំងនេះ ។

## មាត្រា ៣៤ - អត្ថបទសំអាងចំពោះមុខច្បាប់

អនុសញ្ញានេះត្រូវបានរៀបចំឡើងជាភាសាអង់គ្លេស អារ៉ាប់ ចិន អេស្ប៉ាញ បារាំង និងរុស្ស៊ី ហើយអត្ថបទទាំងប្រាំមួយច្បាប់នេះ មានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ។

## មាត្រា ៣៥ - ការចុះបញ្ជី

យោងទៅតាមមាត្រា១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អនុសញ្ញានេះនឹងត្រូវចុះបញ្ជីនៅលេខាធិការដ្ឋានអង្គការសហប្រជាជាតិ តាមសំណើរបស់អគ្គនាយកអង្គការយូណេស្កូ ។

# ឧបសម្ព័ន្ធ

## នីតិវិធីផ្សះផ្សា

### មាត្រា ១ - គណៈកម្មការផ្សះផ្សា

គណៈកម្មការផ្សះផ្សាមួយត្រូវបានបង្កើតឡើង ទៅតាមសំណើរបស់រដ្ឋភាគីណាមួយដែលមានវិវាទ ។ លុះត្រាតែបណ្ដារដ្ឋភាគីទាំងអស់មានការព្រមព្រៀងផ្សេងពីនេះ គណៈកម្មការនេះមានសមាសភាពជាសមាជិកចំនួនប្រាំរូប ដែលក្នុងនោះ រដ្ឋភាគីពាក់ព័ន្ធនីមួយៗចាត់តាំងសមាជិកពីររូប ហើយប្រធានត្រូវជ្រើសរើសតាមការព្រមព្រៀងគ្នាដោយសមាជិកដែលបានចាត់តាំង ។

### មាត្រា ២ - សមាជិកគណៈកម្មការ

ក្នុងករណីមានវិវាទកើតឡើងរវាងរដ្ឋភាគីលើសពីពីរ រដ្ឋភាគី ដែលមានអត្ថប្រយោជន៍ដូចគ្នា ចាត់តាំងសមាជិកគណៈកម្មការរបស់ខ្លួនតាមការព្រមព្រៀងរួមគ្នា ។នៅពេលដែលរដ្ឋភាគីពីរយ៉ាងតិចមានផលប្រយោជន៍ផ្សេងពីគ្នា ឬនៅពេលដែលរដ្ឋភាគីទាំងនោះមិនព្រមព្រៀងគ្នាលើបញ្ហា ដែលចង់ដឹងថាតើខ្លួនមានផលប្រយោជន៍ដូចគ្នាឬយ៉ាងណានោះ ប្រទេសទាំងនោះត្រូវចាត់តាំងសមាជិករបស់ខ្លួនដាច់ដោយឡែកពីគ្នា ។

### មាត្រា ៣ - ការតែងតាំង

ប្រសិនបើ នៅក្នុងរយៈពេលកំណត់ពីរខែ ក្រោយការស្នើបង្កើតគណៈកម្មការផ្សះផ្សាមួយ សមាជិកគណៈកម្មការទាំងអស់ មិនទាន់ត្រូវបានតែងតាំងដោយបណ្ដារដ្ឋភាគីទាំងនោះនៅឡើយទេ អគ្គនាយកអង្គការយូណេស្កូធ្វើការតែងតាំងជាចាំបាច់ក្នុងរយៈពេលកំណត់ថ្មីពីរខែ ទៅតាមសំណើរបស់ភាគីដែលបានស្នើសុំ ។

### មាត្រា ៤ - ប្រធានគណៈកម្មការ

ប្រសិនបើនៅក្នុងរយៈពេលកំណត់ពីរខែ ក្រោយពីបានតែងតាំងសមាជិកគណៈកម្មការចុងក្រោយ ហើយគណៈកម្មការនេះនៅមិនទាន់បានជ្រើសរើសប្រធានរបស់ខ្លួនទៀតនោះ អគ្គនាយកធ្វើការតែងតាំងប្រធាននៅក្នុងរយៈពេលកំណត់ថ្មីពីរខែ ទៅតាមសំណើរបស់រដ្ឋភាគីណាមួយ ។

### មាត្រា ៥ - សេចក្ដីសម្រេច

គណៈកម្មការផ្សះផ្សាធ្វើសេចក្ដីសម្រេច ដោយសំឡេងភាគច្រើននៃសមាជិករបស់ខ្លួន ។ លើកលែងតែរដ្ឋភាគីវិវាទមានការព្រមព្រៀងផ្សងពីនេះ គណៈកម្មការរៀបចំនីតិវិធីផ្ទាល់របស់ខ្លួន ហើយស្នើជាដំណោះស្រាយវិវាទ ដែលភាគីទាំងអស់ត្រូវពិនិត្យដោយសុទ្ធចិត្ត ។

### មាត្រា ៦ - ការមិនព្រមព្រៀង

នៅក្នុងករណីមិនមានការព្រមព្រៀងគ្នាពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការផ្សះផ្សាទេនោះ គណៈកម្មការជាអ្នកសម្រេចថាតើខ្លួនមាន ឬគ្មានសមត្ថកិច្ច ។